00740763 E116

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 09 / 09 / 2011
ម៉ោង (Time/Heure): 11:15
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
Case File/Dossier N° 002/19-09-2007/ECCC/TC

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម **និល ណុន** ជាប្រធាន |
| | ចៅក្រម **Silvia CARTWRIGHT** |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម **Jean-Marc LAVERGNE** |
| | ចៅក្រម **ធូ មណី** |
| កាលបរិច្ឆេទ: | ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១១ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

## សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (ឯកសារ E51/3, E 82, E 88 និង E 92)

**សហព្រះរាជអាជ្ញា**

ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**

នួន ជា

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Elisabeth SIMONNEAU FORT

**មេធាវីជនជាប់ចោទ**

សុន អរុណ
Michiel PESTMAN
Victor KOPPE

## ១. សេចក្តីផ្តើម

១. អង្គជំនុំជម្រះបានទទួលសំណើមួយចំនួនពី នួន ជា ("ជនជាប់ចោទ") ពាក់ព័ន្ធនឹងកិច្ចស៊ើបសួរក្នុងសំណុំរឿងលេខ ០០២។ សំណើទីមួយ ដែលបានលើកឡើងនៅក្នុងអញ្ញត្រកម្មរបស់ជនជាប់ចោទដែលបានធ្វើឡើងស្របទៅនឹងវិធាន ៨៩ នោះ បានលើកឡើងពីការជ្រៀតជ្រែករបស់រាជរដ្ឋាភិបាលកម្ពុជាមកលើដំណើរការស៊ើបអង្កេត ហើយក៏បានលើកឡើងពីភាពលម្អៀង និងមិនមានតម្លាភាពនៅក្នុងដំណើរការស៊ើបអង្កេតផងដែរ[1]។ ហេតុដូច្នេះ សំណើនេះសុំឱ្យបញ្ចប់កិច្ចដំណើរការនីតិវិធី ឬជាជម្រើសមួយទៀតសុំឱ្យបង្អង់កិច្ចដំណើរការនីតិវិធីនានា[2]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនិងសហព្រះរាជអាជ្ញា បានដាក់ចម្លើយតបរបស់ខ្លួនចំពោះអញ្ញត្រកម្មនេះនៅថ្ងៃទី ០៧ និងថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១១ ដាច់ដោយឡែកពីគ្នា[3]។

២. នៅថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១១ ជនជាប់ចោទបានដាក់សំណើមួយទៀតសុំឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការស៊ើបអង្កេតអនុលោមតាមវិធាន ៣៥(២)(ខ) ទៅលើការចោទប្រកាន់ថាមានការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ[4]។ នៅថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១១ ជនជាប់ចោទបានដាក់សំណើមួយទៀតដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងសំណើខាងលើ ដោយស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការស៊ើបអង្កេតលើករណីមួយ ដែលមេធាវីបានលើកឡើងថាជាការរំខានដល់បុគ្គលមួយរូបដែលអាចក្លាយជាសាក្សីសក្តានុពលក្នុងសំណុំរឿងលេខ ០០២[5]។

---

[1] អញ្ញត្រកម្មរួមបញ្ចូលគ្នា, ឯកសារ E51/3, ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ("អញ្ញត្រកម្ម") កថាខណ្ឌ ៣។

[2] អញ្ញត្រកម្ម, កថាខណ្ឌ ៦៥។

[3] ចម្លើយតបរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីចំពោះសារណារបស់ក្រុមភាគីការពារក្តីទាក់ទងនឹងអញ្ញត្រកម្មបឋម (វិធាន ៨៩), ឯកសារ E51/5/4, ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១១, កថាខណ្ឌ ៣២ (ជំទាស់ទៅនឹងអញ្ញត្រកម្មទាំងនេះ ពាក់ព័ន្ធទៅនឹងភាពអាចទទួលយកបាន និងខ្លឹមសាររបស់វា), ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងអញ្ញត្រកម្មបឋមរបស់មេធាវីការពារក្តីអនុលោមតាមវិធាន ៨៩, ឯកសារ E51/5/3/1, ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១១ ("ចម្លើយតបទៅនឹងអញ្ញត្រកម្ម")។

[4] សំណើរបស់លោក នួន ជា សុំបំពេញកិច្ចស៊ើបសួរអនុលោមតាមវិធាន ៣៥, ឯកសារ E82, ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១១ ("សំណើអនុលោមតាមវិធាន ៣៥")។

[5] សំណើលើកទីពីរសុំឱ្យបំពេញកិច្ចស៊ើបសួរ ដោយអនុលោមតាមវិធាន ៣៥, ឯកសារ E92, ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១១ ("សំណើលើកទីពីរអនុលោមតាមវិធាន ៣៥")។

សហព្រះរាជអាជ្ញាបានឆ្លើយតបទៅនឹងសំណើទាំងនេះនៅថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១១ និងថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១១ ដាច់ដោយឡែកពីគ្នា[6]។

៣. ជាចុងក្រោយនៅថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ ជនជាប់ចោទបានដាក់សំណើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងបំពេញកិច្ចស៊ើបសួរមួយចំនួន ដែលសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") បានបដិសេធទាំងស្រុង ឬមួយផ្នែក ក្នុងអំឡុងពេលស៊ើបសួរ[7]។ សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបទៅនឹងសំណើនេះនៅថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១១[8]។

៤. ដោយពិនិត្យឃើញថា សំណើទាំងនេះគឺមានភាពដូចគ្នានោះ ដូច្នេះ អង្គជំនុំជម្រះចេញនូវសេចក្តីសម្រេចរួមមួយ ជាការឆ្លើយតបទៅនឹងសំណើទាំងអស់នេះ[9]។

## ២. សារណា

### ២.១. ការតវ៉ាចំពោះកិច្ចស៊ើបសួរ (អញ្ញត្រកម្ម)

៥. ជនជាប់ចោទបានលើកឡើងថា មានវិការៈសំខាន់ៗចំនួន ០៣ នៅក្នុងកិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបសួរ។ វិការៈទាំងនោះមានដូចជា៖ ការខកខានមិនបានស៊ើបសួរឱ្យបានគ្រប់គ្រាន់លើភស្តុតាងដោះបន្ទុក កង្វះតម្លាភាព និងការស្តាប់យកចម្លើយពុំបានត្រឹមត្រូវ។ ក្នុងចំណោមសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរចំនួន ២៦ ដែលជនជាប់ចោទបានដាក់ មានសំណើចំនួន ២០ ត្រូវបាន

---

[6] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់លោក នួន ជា សុំបំពេញកិច្ចស៊ើបសួរអនុលោមតាមវិធាន ៣៥, លេខឯកសារ E82/1, ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១១ ("ចម្លើយតបអនុលោមតាមវិធាន ៣៥"),ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើសុំបំពេញកិច្ចស៊ើបសួរលើកទីពីររបស់ នួន ជា អនុលោមតាមវិធាន ៣៥, ឯកសារ E92/1, ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១១ ("សំណើលើកទីពីរអនុលោមតាមវិធាន ៣៥"), ឯកសារ E92/1, ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១១ ("ចម្លើយតបលើកទីពីរអនុលោមតាមវិធាន ៣៥")។

[7] សំណើរួមលើកទីមួយសុំបំពេញកិច្ចស៊ើបសួរបន្ថែម, លេខឯកសារ E88, ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ ("សំណើសុំបំពេញកិច្ចស៊ើបសួរ")។

[8] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរួមលើកទី១របស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរបន្ថែម, ឯកសារ E88/2, ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១១ ("ចម្លើយតបទៅនឹងសំណើសុំបំពេញកិច្ចស៊ើបសួរ")។

[9] *សូមមើលបន្ថែម* អនុស្សរណៈដែលមានចំណងជើងថាកាលបរិច្ឆេទសវនាការបឋម, ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១១, ឯកសារ E86 (ដោយគូសបញ្ជាក់ថាអង្គជំនុំជម្រះនឹងពុំស្តាប់ទឡ្ហីករណ៍ផ្ទាល់មាត់លើបញ្ហាណាមួយឡើយ)។

ស.ច.ស បដិសេធទាំងស្រុង ឬមួយផ្នែក[10]។ ជនជាប់ចោទបានអះអាងថា ការដែល ស.ច.ស បដិសេធលើសំណើសុំទាំងនោះ គឺបញ្ជាក់ឱ្យឃើញថា ស.ច.ស ពុំបានស្វែងរកភស្តុតាងដោះបន្ទុកនោះទេ ហើយបង្ហាញឱ្យឃើញនូវភាពលម្អៀងរបស់ ស.ច.ស ក្នុងការស្វែងរកតែភស្តុតាងដាក់បន្ទុកប៉ុណ្ណោះ[11]។

៦. ជនជាប់ចោទបានលើកឡើងទៀតថា រាជរដ្ឋាភិបាលកម្ពុជាបានជ្រៀតជ្រែកមកលើដំណើរការស៊ើបសួរ តាមរយៈការរារាំងមិនឱ្យ ស.ច.ស ស្តាប់ចម្លើយព្រះមហាវីរក្សត្រ សម្តេចព្រះវររាជបិតា នរោត្តម សីហនុ និងមន្ត្រីជាន់ខ្ពស់ចំនួន ០៦ រូបទៀត ហើយរាជរដ្ឋាភិបាលកម្ពុជាក៏បានបន្តការជ្រៀតជ្រែកចូលក្នុងដំណើរការស៊ើបសួរលើសំណុំរឿងលេខ ០០៣ និង០០៤ ផងដែរ[12]។ ជនជាប់ចោទអះអាងទៀតថា ការដែល ស.ច.ស ខកខានមិនបានផ្តល់នូវមូលហេតុនៃសេចក្តីសម្រេចលើសំណើសុំឱ្យមានកិច្ចស៊ើបសួរ ឬមិនបានពន្យល់អំពីវិធីសាស្ត្រក្នុងការស៊ើបសួររបស់ខ្លួន បង្ហាញឱ្យឃើញនូវការខ្វះតម្លាភាព និងមិនអាចធ្វើឱ្យមេធាវីការពារក្តីជឿថា ការស៊ើបសួរធ្វើឡើងដោយមានភាពល្អិតល្អន់ មិនមានភាពលម្អៀង និងមិនមានការជ្រៀតជ្រែកខាងផ្នែកនយោបាយនោះឡើយ[13]។

៧. ជាចុងក្រោយ ជនជាប់ចោទលើកឡើងថា វិការៈដែលមាននៅក្នុងសំណុំរឿងលេខ ០០២ គឺមានលក្ខណៈធ្ងន់ធ្ងរជាសារវ័ន្ត ដែលបញ្ហានេះអាចត្រូវជួសជុលបានលុះត្រាតែការស៊ើបសួរជាថ្មីឡើងវិញទាំងស្រុងប៉ុណ្ណោះ ហើយការដែលធ្វើដូច្នេះគឺអាចហួសពីសមត្ថភាពរបស់អង្គជំនុំជម្រះ ដែលទោះជាក្នុងករណីណាក៏ដោយ ក៏វាមិនយុត្តិធម៌សម្រាប់ជនជាប់ចោទដែរ[14]។ នៅក្នុងការអនុវត្តជាក់ស្តែង វិការៈដែលមាននៅក្នុងសំណុំរឿងនោះគឺមិនអាចជួសជុលបានទេ ហេតុដូច្នេះបណ្តឹង អាជ្ញាត្រូវតែបញ្ចប់។ ជាជម្រើសម្យ៉ាងទៀត ជនជាប់ចោទបានស្នើសុំឱ្យបង្អង់កិច្ចដំណើរការនីតិវិធីជាបណ្តោះអាសន្នដើម្បីធ្វើការស៊ើបសួរបន្ថែម[15]។

[10] សំណើសុំបំពេញកិច្ចស៊ើបសួរ, កថាខណ្ឌ ៣។

[11] អញ្ញត្រកម្ម, កថាខណ្ឌ ៥៨។

[12] អញ្ញត្រកម្ម, កថាខណ្ឌ ៦,១០-១៤,៥៧។

[13] អញ្ញត្រកម្ម, កថាខណ្ឌ ១៦, ៥៩។

[14] អញ្ញត្រកម្ម, កថាខណ្ឌ ៦២។

[15] អញ្ញត្រកម្ម, កថាខណ្ឌ ៦៤-៦៥។

៨. ជាការឆ្លើយតប សហព្រះរាជអាជ្ញាបានលើកឡើងថា សេចក្តីសម្រេចរបស់ ស.ច.ស គឺមានភាពត្រឹមត្រូវ។ ប្រសិនបើអង្គបុរេជំនុំជម្រះយល់ឃើញថាសេចក្តីសម្រេចរបស់ ស.ច.ស មិនត្រឹមត្រូវនោះ ប្រាកដជាអង្គបុរេជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើក្នុងបណ្តឹងឧទ្ធរណ៍នោះហើយ[16]។ ចំពោះការលើកឡើងដែលថា ស.ច.ស មានភាពលម្អៀងក្នុងការស្វែងរកភស្តុតាងដាក់បន្ទុក និងមានការជ្រៀតជ្រែកខាងផ្នែកនយោបាយពីសំណាក់រាជរដ្ឋាភិបាលកម្ពុជានោះ គឺធ្លាប់ត្រូវបានអង្គបុរេជំនុំជម្រះសម្រេច និងបដិសេធរួចហើយ ដោយឡែកសំណើដែលបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះនៅពេលនេះគឺមិនបានបង្ហាញនូវភស្តុតាងថ្មីដើម្បីគាំទ្រចំពោះការលើកឡើងនេះទេ[17]។ បន្ថែមលើនេះ សហព្រះរាជអាជ្ញាយល់ថា វាហាក់បីដូចជាឆាប់ពេកសម្រាប់មេធាវីការពារក្តីដែលចោទប្រកាន់ពីការរំលោភលើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ដោយគ្រាន់តែផ្អែកទៅលើសាក្សីដែលមេធាវីការពារក្តីបានស្នើសុំឱ្យកោះហៅ ហើយដែលចំណុចនេះគួរតែរង់ចាំរហូតដល់អង្គជំនុំជម្រះសាលាដំបូងធ្វើការសម្រេចសិន ថាតើសាក្សីណាខ្លះដែលនឹងត្រូវកោះហៅដើម្បីមកផ្តល់សក្ខីកម្មនៅពេលជំនុំជម្រះ[18]។

៩. សហព្រះរាជអាជ្ញាបានលើកឡើងទៀតថា ក្នុងអំឡុងពេលដែលជនជាប់ចោទបានស្នើសុំឱ្យមានការស៊ើបសួរ ជនជាប់ចោទបានទទួលព័ត៌មានពី ស.ច.ស ពាក់ព័ន្ធនឹងកិច្ចស៊ើបសួរ ហើយនៅគ្រប់ពេលវេលាទាំងអស់ ជនជាប់ចោទមានលទ្ធភាពពេញលេញក្នុងការពិនិត្យមើលសំណុំរឿងដែលត្រូវបានបង្កើតឡើងដោយ ស.ច.ស [19]។ ជាចុងក្រោយ សហព្រះរាជអាជ្ញាបានកត់សម្គាល់ថា អនុលោមតាមយុត្តិសាស្ត្ររបស់ អ.វ.ត.ក និងយុត្តិសាស្ត្រអន្តរជាតិ ការបង្អង់នីតិវិធីគឺជាការជួសជុលមួយដ៏ធំធេង ដែលបន្ទុកនៃភស្តុតាងជាច្រើនត្រូវធ្លាក់ទៅភាគីម្ចាស់សំណើ។ ទោះបីជាក្នុងកាលៈទេសៈណាក៏ដោយ ការបញ្ចប់កិច្ចដំណើរការនីតិវិធីនាពេលបច្ចុប្បន្ន គឺជាវិធានការមួយដែលពុំសមស្របឡើយ[20]។

---

[16] ចម្លើយតបទៅនឹងអញ្ញត្រកម្ម, កថាខណ្ឌ ៧៤-៧៥។

[17] ចម្លើយតបទៅនឹងអញ្ញត្រកម្ម, កថាខណ្ឌ ៦៩, ៧៦-៧៧។

[18] ចម្លើយតបទៅនឹងអញ្ញត្រកម្ម, កថាខណ្ឌ ៧១, ៧៨។

[19] ចម្លើយតបទៅនឹងអញ្ញត្រកម្ម, កថាខណ្ឌ ៧៣។

[20] ចម្លើយតបទៅនឹងអញ្ញត្រកម្ម, កថាខណ្ឌ ៦៣-៦៨, ៧៩។

## ២.២. សំណើមួយចំនួនដែលទាក់ទងទៅនឹងការចោទប្រកាន់អំពីការជ្រៀតជ្រែកចូលកិច្ចការរដ្ឋបាលតុលាការ (វិធាន ៣៥ នៃវិធានផ្ទៃក្នុង)

១០. នៅក្នុងសំណើទីមួយដែលបានធ្វើឡើងអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ជនជាប់ចោទបានលើកឡើងអំពីការជ្រៀតជ្រែកចូលកិច្ចការរដ្ឋបាលតុលាការ ដូចមានរៀបរាប់ក្នុងអញ្ញត្រកម្មរបស់ខ្លួន។ អនុលោមតាមវិធាន ៣៥(២)(ខ) នៃវិធានផ្ទៃក្នុង ជនជាប់ចោទក៏បានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងបំពេញកិច្ចស៊ើបសួរទៅលើការចោទប្រកាន់ទាំងនេះ។ ជនជាប់ចោទ អះអាងថា មូលដ្ឋានគតិយុត្តិជាស្តង់ដារដែលអនុវត្តសម្រាប់ការស៊ើបសួរ តាមវិធាននេះ គឺមានហេតុផលដែលអាចជឿបានថា ការជ្រៀតជ្រែកពិតជាកើតមានឡើង[21]។ ដោយទទួលស្គាល់ថា នាពេលកន្លងមក ជនជាប់ចោទធ្លាប់បានលើកសំណើស្រដៀងគ្នានេះទៅ ស.ច.ស និងអង្គបុរេជំនុំជម្រះនោះដោយលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានភារកិច្ចប្រកបដោយឯករាជ្យភាពក្នុងការស៊ើបអង្កេត ដោយយោងទៅលើផលប៉ះពាល់នៃការចោទប្រកាន់ទាំងនេះមកលើសិទ្ធិរបស់ ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ បន្ថែមលើចំណុចនេះ ការវិវឌ្ឍន៍នាពេលបច្ចុប្បន្នពុំបង្កើតបានជាផ្នែកណាមួយនៃសំណើនាពេលកន្លងមករបស់ជនជាប់ចោទឡើយ[22]។

១១. សំណើទីពីររបស់ជនជាប់ចោទដែលបានធ្វើឡើងអនុលោមតាមវិធាន ៣៥ នោះ គឺពាក់ព័ន្ធនឹងករណីមួយដែលសមាជិកគ្រួសាររបស់ [redacted] (បុគ្គលដែលអាចជាជនសង្ស័យនៅចំពោះមុខ អ.វ.ត.ក) ត្រូវបានចោទថាបានទាក់ទងជាមួយបុគ្គលដែលអាចជាសាក្សីសក្តានុពល ក្នុងសំណុំរឿងលេខ ០០២[23]។

១២. ក.ស.ព បានជំទាស់ទៅនឹងសំណើទីមួយ។ សហព្រះរាជអាជ្ញាបានលើកឡើងថា វាមិនត្រឹមត្រូវទេសម្រាប់អង្គជំនុំជម្រះសាលាដំបូង ដែលត្រូវធ្វើការស៊ើបអង្កេតទៅលើបញ្ហាដែលបានកើតមានរួចហើយក្នុងអំឡុងពេលស៊ើបសួរនោះ។ ប៉ុន្តែ ក្នុងករណីមានបញ្ហាថ្មីណាមួយកើតឡើងនៅក្នុងដំណាក់កាលជំនុំជម្រះ ជនជាប់ចោទមានសិទ្ធិដាក់សំណើដូចនេះបាន ដោយអនុលោមតាមវិធាន

[21] សំណើអនុលោមតាមវិធាន៣៥, កថាខណ្ឌ ១៧។

[22] សំណើអនុលោមតាមវិធាន ៣៥, កថាខណ្ឌ ១០,២៩ (ដោយកត់សម្គាល់ជាឧទាហរណ៍នូវប្រសាសន៍របស់នាយករដ្ឋមន្ត្រីក្នុងអំឡុងពេលអគ្គលេខាធិការ អ.ស.ប ធ្វើទស្សនកិច្ច នៅកម្ពុជាកាលពីថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១០)។

[23] សំណើអនុលោមតាមវិធាន ៣៥, កថាខណ្ឌ ២ (ដោយកត់សម្គាល់នូវសម្តីរបស់សាក្សីរូបនោះក្នុងអំឡុងពេល ស.ច.ស ស្តាប់ចម្លើយក្នុងឆ្នាំ ២០០៨)។

៣៥[24]។ ទោះជាយ៉ាងណាក្តី សហព្រះរាជអាជ្ញាបានគាំទ្រឱ្យមានកិច្ចស៊ើបសួរដែលមានកំហិតទៅលើការចោទប្រកាន់ទាំងប៉ុន្មានដែលមាននៅក្នុងសំណើទី២ អនុលោមតាមវិធាន ៣៥ ដើម្បីសម្រេចថាតើ [redacted] ពិតជាបានទាក់ទងជាមួយនឹងសាក្សីក្នុងសំណុំរឿងលេខ ០០២ ដែរ ឬយ៉ាងណា[25]។ ប៉ុន្តែ ការចោទប្រកាន់ណាមួយពាក់ព័ន្ធនឹងសំណុំរឿង ០០៣ និង ០០៤ ពុំពាក់ព័ន្ធនឹងចំណាត់ការរបស់អង្គជំនុំជម្រះលើសំណុំរឿង ០០២ ឡើយ[26]។

## ២.៣. សំណើរួមស្នើសុំឱ្យមានកិច្ចស៊ើបសួរ

១៣. នៅក្នុងសំណើសុំបំពេញកិច្ចស៊ើបសួររបស់ខ្លួន ជនជាប់ចោទបានអះអាងថា សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរចំនួន ២០ ដែលត្រូវបានបដិសេធទាំងស្រុង ឬមួយផ្នែកដោយ ស.ច.ស នោះ គួរត្រូវបានអង្គជំនុំជម្រះទទួលយក ដោយអនុលោមតាមវិធាន ៣៩ នៃវិធានផ្ទៃក្នុង។ ជនជាប់ចោទអះអាងថា ចំណុចពាក់ព័ន្ធនឹងបញ្ហានេះគឺថា តើកិច្ចស៊ើបសួរថ្មីមានភាពចាំបាច់ដែរ ឬទេ ក្នុងន័យថាកិច្ចស៊ើបសួរទាំងអស់នេះអាចឈានទៅដល់ការរកឃើញឯកសារ ឬព័ត៌មានពាក់ព័ន្ធ ដែលមានតម្លៃជាភស្តុតាងបឋម (*prima facie*)[27]។ ជនជាប់ចោទបានលើកឡើងថា កិច្ចស៊ើបសួរថ្មីដែលខ្លួនបានស្នើសុំនេះគឺមានភាពចាំបាច់ ដោយសារតែកិច្ចស៊ើបសួរទាំងនេះមានផលប៉ះពាល់ទៅ លើសិទ្ធិរបស់ខ្លួនក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ (បណ្តាលមកពីកិច្ចស៊ើបសួរដែលត្រូវបានចោទប្រកាន់ថាមានចំណុចខ្វះចន្លោះ) និងដើម្បីដាក់បញ្ចូលទឡ្ហីករណ៍ទាំងប៉ុន្មានដែលមាននៅក្នុងសំណើសុំបំពេញកិច្ចស៊ើបសួរដំបូង ដើម្បីបង្ហាញអំពីភាពពាក់ព័ន្ធនៃសំណើនីមួយៗ[28]។ ជាចុងក្រោយ ជនជាប់ចោទអះអាងថាការស៊ើបអង្កេតទៅលើអំពើដែលស្ថិតនៅក្រៅយុត្តាធិការតាមពេលវេលារបស់ អ.វ.ត.ក គឺចាំបាច់ត្រូវធ្វើក្នុងគោលបំណងដើម្បីបង្ហាញនូវបរិបទដែលពាក់ព័ន្ធ[29]។

១៤. ជាការឆ្លើយតប សហព្រះរាជអាជ្ញាបានលើកឡើងថា ការបដិសេធរបស់ ស.ច.ស ទៅលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរទាំងអស់ដែលបានលើកឡើងនៅក្នុងសំណើនេះ គឺផ្អែកទៅលើសំអាង

[24] ចម្លើយតបអនុលោមតាមវិធាន ៣៥, កថាខណ្ឌ ៣។

[25] ចម្លើយតបលើកទីពីរអនុលោមតាមវិធាន ៣៥, កថាខណ្ឌ ៣-៦។

[26] ចម្លើយតបលើកទីពីរអនុលោមតាមវិធាន ៣៥, កថាខណ្ឌ ២។

[27] សំណើសុំបំពេញកិច្ចស៊ើបសួរ, កថាខណ្ឌ ៩-១១។

[28] សំណើសុំបំពេញកិច្ចស៊ើបសួរ, កថាខណ្ឌ ១៣, ១៥-១៨ (ដោយលើកឡើងនូវមូលដ្ឋានអង្គហេតុដែលដូចមាននៅក្នុងអញ្ញត្រកម្មរបស់ជនជាប់ចោទ ពាក់ព័ន្ធនឹងចំណុចខ្វះខាតនៃកិច្ចស៊ើបសួរដែលត្រូវបានចោទប្រកាន់)។

[29] សំណើសុំបំពេញកិច្ចស៊ើបសួរ, កថាខណ្ឌ ១២។

ហេតុដែលមានលក្ខណៈត្រឹមត្រូវ និងពុំមែនបណ្តាលមកពីវិការៈនៃកិច្ចស៊ើបសួរនោះទេ។ សហព្រះរាជអាជ្ញាក៏បានអះអាងទៀតថា វិសាលភាពនៃវិធាន ៩៣ នៃវិធានផ្ទៃក្នុង គួរត្រូវបានកំហិតត្រឹមកិច្ចស៊ើបសួរទៅលើអំពើជាក់លាក់ណាមួយ ដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងអង្គហេតុ ដែលជនជាប់ចោទត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ ហើយសំខាន់នោះគឺដើម្បីបញ្ជាក់ការពិត[30]។ ហេតុដូច្នេះ អង្គជំនុំជម្រះពិនិត្យឃើញថាសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែមរបស់ នួន ជា គឺមានភាពមិនច្បាស់លាស់ ឬមិនពាក់ព័ន្ធ[31]។

## ៣. អំពីសម្អាងហេតុ

### ៣.១. ភាពអាចទទួលយកបាននៃសំណើសុំបញ្ចប់ ឬបង្អង់កិច្ចដំណើរការនីតិវិធី

១៥. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សំណើសុំទាំងអស់នេះបង្កើតបានជាផ្នែកមួយនៃអញ្ញត្រកម្មរបស់ជនជាប់ចោទដែលបានដាក់អនុលោមតាមវិធាន ៨៩ នៃផ្ទៃក្នុង។ វិធាន៨៩(១)(គ) បានចែងយ៉ាងច្បាស់ថា អង្គជំនុំជម្រះសាលាដំបូងអាចធ្វើការពិចារណាអំពីមោឃភាពនីតិវិធីបានតែ "ក្រោយពេលមានដីកាដំណោះស្រាយ" ប៉ុណ្ណោះ[32]។ ជាទូទៅ នៅក្នុងដំណាក់កាលស៊ើបសួរ ការជំទាស់ទាក់ទងទៅនឹងដំណើរការនីតិវិធី ឬសេចក្តីសម្រេចនានាដែលបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ ត្រូវតែលើកឡើងជាមួយនឹងស្ថាប័នដែលមានសមត្ថកិច្ចមុនពេលដីកាដំណោះស្រាយចូលជាស្ថាពរ។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ជាការពិតជនជាប់ចោទបានលើកឡើងអំពីការជំទាស់នេះជាមួយសហចៅក្រមស៊ើបអង្កេត និងអង្គបុរេ-ជំនុំជម្រះនៅក្នុងដំណាក់កាលស៊ើបសួរ ដូច្នេះហើយការជំទាស់ទាំងនេះគឺជាកម្មវត្ថុនៃសេចក្តី-សម្រេចពីពេលមុនរបស់ស្ថានប័នទាំងពីរខាងលើ[33]។

---

[30] សំណើសុំបំពេញកិច្ចស៊ើបសួរ, កថាខណ្ឌ ៣-៥។

[31] សំណើសុំបំពេញកិច្ចស៊ើបសួរ, កថាខណ្ឌ ៥។

[32] វិធានផ្ទៃក្នុង ៨៩(១)(គ)។

[33] *សូមមើល ឧទាហរណ៍* "ចម្លើយតបរបស់សហចៅក្រមស៊ើបអង្កេតទៅនឹង "សំណើសុំបំពេញកិច្ចស៊ើបសួរ" ដែលក្នុងនោះពាក់ព័ន្ធនឹងវិធីសាស្ត្ររបស់សហចៅក្រមស៊ើបអង្កេតទាក់ទិនទៅនឹងកិច្ចស៊ើបសួរ" ឯកសារ D171/5 ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០៩។ "សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការបដិសេធតាមការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើលើកទី៣ របស់ អៀង សារី សុំឱ្យបំពេញកិច្ចស៊ើបសួរ" ឯកសារ D171/4/5 ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០៩។

១៦. ជនជាប់ចោទបានលើកពីមូលហេតុនៃអញ្ញត្រកម្មរបស់ខ្លួន ដោយផ្អែកទៅលើវិធាន ៨៩(១)(ខ) នៃវិធានផ្ទៃក្នុង។ ដូចដែលមានចែងនៅក្នុងអត្ថបទជាភាសាអង់គ្លេស អនុវិធានខាងលើនេះចែងថា អញ្ញត្រកម្មអាចផ្អែកលើ "បញ្ហាណាមួយដែលទាក់ទងនឹងការរលត់បណ្តឹងអាជ្ញា"។ អត្ថបទជាភាសាបារាំង និងភាសាខ្មែរនៃវិធាន ៨៩(១)(ខ) ស្របគ្នាជាមួយនឹងទស្សនទាននៃការរលត់បណ្តឹងអាជ្ញា (*l'extinction de l'action publique*) ដែលមានចែងនៅក្នុងមាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ ("CCP")។ មាត្រា ៧ នេះមិនបានរួមបញ្ចូលអំពីវិការៈក្នុងអំឡុងពេលស៊ើបសួរនោះទេ ប៉ុន្តែ មាត្រានេះបានចែងអំពីមូលហេតុនានានៃការរលត់បណ្តឹងអាជ្ញា ដែលមូលហេតុទាំងនោះមានដូចជា៖ (១) មរណភាពនៃជនល្មើស (២) ការផុតអាជ្ញាយុកាល (៣) ការលើកលែងទោសជាទូទៅ (៤) និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ និង (៥) អាជ្ញាអស់ជំនុំ[34]។

១៧. ហេតុដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា វិធាន ៨៩(១)(ខ) គឺត្រូវបានកម្រិតត្រឹមតែមូលដ្ឋានដែលបានរៀបរាប់ខាងលើប៉ុណ្ណោះ[35]។ ផ្អែកលើមូលដ្ឋាននេះ អង្គជំនុំជម្រះសម្រេចថាផ្នែកមួយចំនួននៃអញ្ញត្រកម្មរបស់ជនជាប់ចោទដែលបានតវ៉ាអំពីសុពលភាពនៃកិច្ចស៊ើបសួរ ដោយផ្អែកលើមូលហេតុវិការៈនៅក្នុងកិច្ចដំណើរការនីតិវិធី ភាពលម្អៀង ឬការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ គឺមិនអាចទទួលយកជាអញ្ញត្រកម្មបានទេ។ សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរដែលអះអាងថា ការស៊ើបសួរគឺមានវិការៈខាងនីតិវិធី អង្គជំនុំជម្រះកត់សម្គាល់ផងដែរថា

---

[34] មាត្រា ៧ (ភាសាបារាំង) នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ដែលមានចំណងជើងថា *extinction de l'action publique* ) ចែងថា: *"Les causes d'extinction de l'action publique sont: 1) la mort de l'auteur de l'infraction; 2) la prescription; 3) l'amnistie; 4) l'abrogation de la loi pénale; 5) l'autorité de la chose jugée. Lorsque l'action publique est éteinte, les poursuites pénales ne peuvent plus être engagées ou doivent cesser."* វិធាន ៨៩ (១)(ខ) (ភាសាបារាំង) ចែងថា: *"Les exceptions préliminaires concernent: a) La compétence de la Chambre; b) L'extinction de l'action publique; c) La nullité d'actes de procédure accomplie postérieurement à la décision de renvoi."*

[35] នៅក្នុងកាលៈទេសៈមួយចំនួន ដែលមិនពាក់ព័ន្ធទៅនឹងបរិបទបច្ចុប្បន្ននេះទេ មាត្រា ៨ អាចចែងអំពីមូលដ្ឋានផ្សេងៗទៀតដើម្បីបញ្ចប់កិច្ចដំណើរការនីតិវិធី។ ទោះបីជាយ៉ាងណាក៏ដោយ មូលហេតុទាំងអស់នេះត្រូវតែ "ធ្វើការចែងឲ្យបានច្បាស់លាស់នៅក្នុងច្បាប់ផ្សេងទៀត" (*សូមមើល* មាត្រា ៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា: *"Lorsque des lois particulières le prévoient expressément, l'action publique peut également s'éteindre: 1) par une transaction avec l'Etat; 2) par le retrait de la plainte, dans le cas où la plainte est la condition nécessaire des pousuites pénales; 3) par le paiement d'une amende forfaitaire ou transactionnelle."*)

វិធានផ្ទៃក្នុងមិនបានចែងអំពីការពិនិត្យឡើងវិញដោយអង្គជំនុំជម្រះសាលាដំបូង អំពីភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរក្រោយពេលទទួលបានសំណុំរឿងក្តីនេះទេ[36]។

១៨. នៅពេលយោងលើវិធាននីតិវិធីដែលបានបង្កើតនៅកម្រិតអន្តរជាតិ[37] អង្គជំនុំជម្រះបានធ្វើការកត់សម្គាល់អំពីលក្ខខណ្ឌចាំបាច់ខ្ពស់បំផុតសម្រាប់ការយល់ព្រមឱ្យបញ្ចប់ ឬបង្អង់កិច្ចដំណើរការនីតិវិធីនោះ[38]។ ក្របខណ្ឌច្បាប់របស់ អ.វ.ត.ក ពាក់ព័ន្ធនឹងកិច្ចស៊ើបសួរគឺមាននូវបទប្បញ្ញត្តិខាងនីតិវិធីគ្រប់គ្រាន់ដែលការពារដល់ជនជាប់ចោទ រួមទាំងឱកាសក្នុងការលើកជូនសហចៅក្រមស៊ើបអង្កេតអំពីបញ្ហាផ្សេងៗ និងការធ្វើបណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះលើសេចក្តីសម្រេចនានា

[36] វិធានផ្ទៃក្នុង ៧៦(៧) ចែងថា "លើកលែងតែជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ ដីកាដំណោះស្រាយត្រូវកែតម្រូវកំហុសនៃការមិនគោរពវិធានបញ្ញត្តិក្នុងការស៊ើបសួរ។ គ្មានបញ្ហាណាមួយដែលពាក់ព័ន្ធនឹងកំហុសនីតិវិធីបែបនេះ អាចត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬ អង្គជំនុំជម្រះតុលាការកំពូលឡើយ"។

[37] *សូមមើល* មាត្រា៣៣ថ្មី នៃច្បាប់ អ.វ.ត.ក (ដែលអនុញ្ញាតឱ្យមានដំណោះស្រាយទៅលើវិធាននីតិវិធីដែលត្រូវបានបង្កើតឡើងនៅកម្រិតអន្តរជាតិនៅពេលដែលវិធាននីតិវិធីកម្ពុជាជាធរមានមិនមានការពាក់ព័ន្ធជាមួយនឹងបញ្ហាពិសេសទេ នៅពេលដែលគ្មានភាពច្បាស់លាស់ទាក់ទិននឹងការបកស្រាយ ឬការអនុវត្តវិធានទាំងនេះ ឬប្រសិនបើមានបញ្ហាចោទទាក់ទិនទៅនឹងភាពស៊ីសង្វាក់គ្នារវាងវិធានទាំងនេះជាមួយនឹងបទដ្ឋានអន្តរជាតិនានា)។

[38] ការបញ្ចប់ ឬការបង្អង់កិច្ចដំណើរការនីតិវិធី នៅពេលខ្លះបានទទួលការអនុញ្ញាតពីតុលាការអន្តរជាតិផ្សេងៗ ប៉ុន្តែមានករណីបែបនេះតិចតួចប៉ុណ្ណោះ និងឆ្លុះបញ្ចាំងពីស្ថានភាពដែលក្នុងនោះ ការមិនបន្តកិច្ចដំណើរការនីតិវិធីត្រូវបានពិចារណាឃើញថា ជាដំណោះស្រាយតែមួយគត់ដែលសមស្របដើម្បីធានាអំពីភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី ឬមិនដូច្នេះទេ ជាការចាំបាច់ដើម្បីជាផលប្រយោជន៍នៃភាពយុត្តិធម៌ (សូមមើល ឧទាហរណ៍ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Karadzic* សេចក្តីសម្រេចលើញត្តិសុំបង្អង់កិច្ចដំណើរការនីតិវិធី សំណុំរឿង IT-95-5/18-T អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១០ កថាខណ្ឌ ៤ (ដោយទទួលស្គាល់ថា ដំណោះស្រាយខ្លាំងបំផុតនៃការផ្អាកកិច្ចដំណើរការនីតិវិធីអាចត្រូវបានអនុញ្ញាត នៅពេលដែលការរំលោភធ្ងន់ធ្ងរលើសិទ្ធិមនុស្សរបស់ជនជាប់ចោទធ្វើឱ្យការជំនុំជម្រះក្តីប្រកបដោយភាពយុត្តិធម៌មិនអាចធ្វើបាន)។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Lubanga Dyilo* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ Thomas Lubanga Dyilo ប្រឆាំងនឹង សេចក្តីសម្រេចលើការជំទាស់ របស់មេធាវីការពារក្តីទៅនឹងយុត្តាធិការរបស់តុលាការ [...] អង្គជំនុំជម្រះតុលាការកំពូល ICC (ICC-01/04-01/06-772) ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៦ កថាខណ្ឌ ៣០។ សូមមើលផងដែរ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង *Bararyagwiza* សាលដីកា សំណុំរឿង ICTR-97-19 អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ កថាខណ្ឌ ៧៧, ១០៦ (ដែលបានអនុញ្ញាតតាមញត្តិសុំបញ្ចប់កិច្ចដំណើរការនីតិវិធី នៅពេលដែលការពន្យាពេលហួសហេតុមានភាពធ្ងន់ធ្ងរ រីឯការបញ្ចប់ការចោទប្រកាន់គឺជាដំណោះស្រាយតែមួយគត់ដែលមាន) ដែលត្រូវបានពិចារណានៅក្នុង រឿងក្តី រដ្ឋអាជ្ញា តទល់នឹង *Barayagyiza* សំណុំរឿង ICTR-97-19, ICTR អង្គជំនុំជម្រះតុលាការកំពូលនៃរបស់តុលាការ ICTR សាលដីកា (សំណើរបស់រដ្ឋអាជ្ញាសុំពិនិត្យឡើងវិញ ឬធ្វើការពិចារណាឡើងវិញ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០០ កថាខណ្ឌ ៦៥ (ដោយអនុវត្តឡើងវិញនូវនីតិវិធីដោយផ្អែកលើអង្គហេតុថ្មីៗ)។

00740773



របស់សហចៅក្រមស៊ើបអង្កេតផងដែរ ក្នុងករណីចាំបាច់[39]។ ដូចដែលបានលើកឡើងខាងលើ ជនជាប់ចោទបានប្រើប្រាស់នូវយន្តការជាច្រើននៅចំពោះមុខអង្គបុរេជំនុំជម្រះ[40]។ អង្គជំនុំជម្រះសាលាដំបូងមិនមែនជាសាលាឧទ្ធរណ៍ ហើយក៏មិនមែនជាស្ថាប័នដែលត្រូវត្រួតពិនិត្យឡើងវិញទៅលើសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះនោះទេ។ លើសពីនេះទៀត មកដល់ពេលនេះ ជនជាប់-ចោទមិនបានចង្អុលបង្ហាញអំពីផលប៉ះពាល់ជាក់ស្តែងនៃភាពខ្វះចន្លោះនៅក្នុងកិច្ចស៊ើបសួរនៅក្នុងសំណុំរឿងលេខ ០០២ ទាក់ទងនឹងការជំនុំជម្រះដោយយុត្តិធម៌ ហើយក៏មិនបានបង្ហាញផងដែរថាការជួសជុលដូច្នេះគឺជាមធ្យោបាយតែមួយគត់ដែលមានសម្រាប់អង្គជំនុំជម្រះដើម្បីដោះស្រាយការរំលោភបំពានដែលបានលើកឡើងនេះ[41]។ ហេតុដូច្នេះ មិនមាននូវមូលដ្ឋានណាមួយ ដែលអង្គ-ជំនុំជម្រះត្រូវបង្អង់កិច្ចដំណើរការនីតិវិធីនោះឡើយ។

## ៣.២ សំណើរួមសុំបំពេញកិច្ចស៊ើបសួរ

១៩. ក្នុងអំឡុងពេលស៊ើបសួរដែលបានប្រើរយៈពេលជិតពីរឆ្នាំកន្លះនោះ ជនជាប់ចោទមានឱកាសច្រើនដើម្បីស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតបំពេញនូវរាល់កិច្ចស៊ើបសួរ ដែលជនជាប់ចោទយល់ឃើញថាមានភាពពាក់ព័ន្ធ ហើយក៏មានឱកាសក្នុងការតវ៉ាទៅនឹងការបដិសេធណាមួយរបស់សហចៅក្រមស៊ើបអង្កេតលើសំណើសុំទាំងនេះទៅអង្គបុរេជំនុំជម្រះផងដែរ ក្នុងករណីចាំបាច់[42]។

---

[39] វិធាន ៣៤, ៥៥(១០) និង ៧៤(៣) នៃវិធានផ្ទៃក្នុង ។

[40] *សូមមើល* កំណត់សម្គាល់ ៣៣ ខាងលើ។ សំណើសុំបង្អង់កិច្ចដំណើរការនីតិវិធីក៏ត្រូវបានស្នើសុំ និងវិនិច្ឆ័យផងដែរ នៅចំពោះមុខអង្គបុរេជំនុំជម្រះ (សូមមើល ឧទាហរណ៍ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតបដិសេធលើសំណើសុំព្យួរកិច្ចស៊ើបសួរ ដោយមូលហេតុរំលោភនីតិវិធី ឯកសារ D264/2/6 ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១០ កថាខណ្ឌ ២៧ (ដោយសម្រេចថា ត្រូវតែមានភស្តុតាងធ្វើឱ្យអង្គបុរេជំនុំជម្រះជឿជាក់ថា កំហុសឆ្គងដែលរងការចោទប្រកាន់នោះ ពិតជាធ្វើឱ្យមានការរំលោភសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ហើយការរំលោភបំពាននេះមានលក្ខណៈធ្ងន់ធ្ងរ ទើបអង្គបុរេជំនុំជម្រះអាចសម្រេចព្យួរកិច្ចស៊ើបសួរបាន)។

[41] *សូមមើលបន្ថែមទៀត* "សេចក្តីណែនាំដល់ភាគីពាក់ព័ន្ធនឹងអញ្ញត្រកម្ម និងបញ្ហាពាក់ព័ន្ធ" ឯកសារ E51/7 ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១ (ដែលបង្ហាញថា ជាការឆ្លើយតបទៅនឹងកំហុសដែលទទួលរងការចោទប្រកាន់ នៅក្នុងកិច្ចស៊ើបសួរ បញ្ហាណាមួយដែលទទួលរងការចោទប្រកាន់ថាប៉ះពាល់ដល់ភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីអាចត្រូវបាន លើកឡើងនៅចំពោះមុខអង្គជំនុំជម្រះនៅពេលជំនុំជម្រះក្តីមួយករណីម្តងៗ)។

[42] សំណុំរឿងក្តី ០០២ ត្រូវបានបញ្ជូនទៅសហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧។ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ភាគីនានាថា កិច្ចស៊ើបសួរត្រូវបានបញ្ចប់នៅថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១០ (*សូមមើល* ដីកាដំណោះស្រាយដែលត្រូវបានកែប្រែ កថាខណ្ឌ ៣, ១៣)។

នៅពេលដែលមានការបដិសេធពីសហចៅក្រមស៊ើបអង្កេតទៅលើសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរណាមួយដោយយល់ថាជាការលម្អៀងទៅរកភស្តុតាងដាក់បន្ទុក សិទ្ធិក្នុងការប្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះត្រូវបានធានាដើម្បីការពារសិទ្ធិរបស់ជនជាប់ចោទ។ ជនជាប់ចោទមិនបានបង្ហាញថាហេតុអ្វីបានជាអង្គជំនុំជម្រះសាលាដំបូងពេលនេះត្រូវតែយល់ព្រមតាមសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរនានាដែលបានគូសបញ្ជាក់ដើម្បីធានានូវភាពយុត្តិធម៌នៃការជំនុំជម្រះក្តីនោះទេ។ លើសពីនេះទៀត សហព្រះរាជអាជ្ញាគឺជាអ្នកដែលទទួលបន្ទុកបង្ហាញភស្តុតាងនៅពេលជំនុំជម្រះក្តីពាក់ព័ន្ធទៅនឹងរាល់ការចោទប្រកាន់ទាំងអស់ ប្រឆាំងនឹងជនជាប់ចោទនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ អង្គជំនុំជម្រះយល់ឃើញថា វាជាការជំនុំជម្រះក្តីមួយប្រកបដោយភាពយុត្តិធម៌ និងជាសាធារណៈ ព្រោះជនជាប់ចោទមានឱកាសក្នុងការស្នើសុំឲ្យអង្គជំនុំជម្រះកោះហៅសាក្សីដោះបន្ទុក បង្ហាញភស្តុតាងជាឯកសារ ឬភស្តុតាងផ្សេងទៀតដែលចាំបាច់ដើម្បីបញ្ជាក់ការពិតសួរសំណួរទៅកាន់សាក្សីរបស់ភាគីម្ខាងទៀត និង តតាំងជាមួយនឹងភស្តុតាងនានា ព្រមទាំងការចោទប្រកាន់ផ្សេងៗមកលើគាត់ ដែលជាការជួសជុល ភាពខ្វះចន្លោះនៃកិច្ចស៊ើបសួរដែលត្រូវបានចោទប្រកាន់មកទល់នឹងពេលនេះ[43]។

២០. ពាក់ព័ន្ធទៅនឹងសំណើសុំបំពេញកិច្ចស៊ើបសួររបស់ជនជាប់ចោទ ដែលទាក់ទិនទៅនឹងហេតុការណ៍ទាំងឡាយដែលមិនស្ថិតនៅក្នុងអំឡុងពេលនៃការចោទប្រកាន់ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា អង្គជំនុំជម្រះត្រូវធ្វើការថ្លឹងថ្លែងនូវសំណើសុំនេះជាមួយនឹងកាតព្វកិច្ចរបស់អង្គជំនុំជម្រះក្នុងការការពារសិទ្ធិរបស់ជនជាប់ចោទ ដែលត្រូវទទួលបាននូវការជំនុំជម្រះក្តីដោយឆាប់រហ័ស។ អង្គជំនុំជម្រះបានធ្វើការសម្រេចរួចហើយថា អង្គជំនុំជម្រះនឹងធ្វើការពិចារណាទៅលើបញ្ហាបរិបទប្រវត្តិសាស្ត្រ និងព្រឹត្តិការណ៍នៅខាងក្រៅយុត្តាធិការតាមពេលវេលារបស់ អ.វ.ត.ក តែនៅពេលណាដែលមានការបង្ហាញឲ្យឃើញថាវាមានភាពពាក់ព័ន្ធទៅនឹងបញ្ហាដែលស្ថិតនៅក្នុង

---

43 សំណើជាច្រើនក្នុងចំណោមសំណើសុំបំពេញកិច្ចស៊ើបសួរដែលបានលើកឡើងបានស្នើសុំធ្វើកិច្ចសម្ភាសន៍ជនទាំងឡាយណាដែលជនជាប់ចោទចាប់តាំងពីពេលនោះមកបានស្នើឲ្យធ្វើការសួរដេញដោលក្នុងនាមជាសាក្សីនៅពេលជំនុំជម្រះក្តី (សូមមើលឧទាហរណ៍ សេចក្តីសង្ខេបដែលត្រូវបានធ្វើបច្ចុប្បន្នភាពរបស់ នួន ជា អំពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្នើសុំកោះហៅ ឯកសារ E93/4 ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១១ និងសំណើរបស់ នួន ជា សុំបន្ថែមសាក្សី និងបន្តសវនាការបឋម ឯកសារ E93/9 ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១១)។ សំណើសុំទាំងអស់នេះបច្ចុប្បន្នកំពុងស្ថិតក្រោមការ ពិចារណារបស់អង្គជំនុំជម្រះ។ *សូមមើលបន្ថែមទៀត* វិធានផ្ទៃក្នុង ៩៣(១) (ដែលអនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យមានកិច្ចស៊ើបសួរបន្ថែមនៅពេលដែលអង្គជំនុំជម្រះពិចារណាឃើញថាកិច្ចស៊ើបសួរថ្មីមានភាពចាំបាច់)។

យុត្តាធិការរបស់ អ.វ.ត.ក និងនៅក្នុងវិសាលភាពនៃការជំនុំជម្រះ ដូចដែលបានកំណត់ដោយអង្គជំនុំជម្រះតែប៉ុណ្ណោះ[44]។

## ៣.៣ សំណើសុំមានាធ្វើឡើងតាមវិធាន ៣៥

២១. ពាក់ព័ន្ធទៅនឹងការចោទប្រកាន់របស់ជនជាប់ចោទអំពីការជ្រៀតជ្រែកទៅក្នុងកិច្ចការរដ្ឋបាល-តុលាការ ឬការជ្រៀតជ្រែកខាងនយោបាយនៅក្នុងសំណុំរឿងលេខ ០០៣ និង ០០៤ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា វិធាន ៣៥(២) នៃវិធានផ្ទៃក្នុង មានចែងអំពីកិច្ចស៊ើបសួរទៅលើការចោទប្រកាន់បែបនេះ "នៅពេលដែលសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះមានហេតុផលដែលនាំឱ្យជឿបានថា ជនណាម្នាក់បានធ្វើការជ្រៀតជ្រែកទៅក្នុងកិច្ចការរដ្ឋបាលតុលាការដោយបានដឹងជាមុន និងដោយចេតនា"[45]។ វិធាននេះក៏បានចែងផងដែរថា កិច្ចស៊ើបសួរដែលធ្វើឡើងដោយអនុលោមតាមវិធាននេះ អាចនឹងត្រូវបានអនុវត្តដោយប្រសិទ្ធភាព ដោយស្ថាប័នតុលាការដែលទទួលសំណុំរឿងនេះ។ ដោយសារក្នុងពេលបច្ចុប្បន្ន រឿងក្តីទាំងអស់នេះកំពុងស្ថិតនៅក្នុងដំណាក់កាលស៊ើបសួរ ដូច្នេះ ជាដំបូង ស្ថាប័នដែលមានសមត្ថកិច្ចនោះគឺសហចៅក្រមស៊ើបអង្កេត ហើយបន្ទាប់មកគឺ អង្គបុរេជំនុំជម្រះក្នុងករណីមានបណ្តឹងឧទ្ធរណ៍[46]។ ដោយសារតែសំណើសុំលើកទីមួយដែលធ្វើ ឡើងតាមវិធាន៣៥ មិនបានកំណត់អំពីផលប៉ះពាល់ជាក់ស្តែងនៃការចោទប្រកាន់ទាំងអស់នេះទៅ លើភាពយុត្តិធម៌នៃកិច្ចដំណើរការជំនុំជម្រះក្តីនៅក្នុងសំណុំរឿងលេខ ០០២ (ដែលជាសំណុំរឿងដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលនោះ) ហេតុដូច្នេះ សំណើសុំនេះគប្បីត្រូវបានបដិសេធ។

២២. ផ្ទុយទៅវិញ សំណើសុំលើកទីពីររបស់ជនជាប់ចោទដែលបានធ្វើឡើងតាមវិធាន ៣៥ បានចោទប្រកាន់ពីការជ្រៀតជ្រែក ឬការប្រព្រឹត្តខុសពាក់ព័ន្ធទៅនឹងបុគ្គលម្នាក់ដែលអាចជាសាក្សីក្នុងសំណុំរឿងលេខ ០០២។ ដើម្បីអនុវត្តការទទួលខុសត្រូវរបស់ខ្លួនក្នុងការធានាឱ្យមាននូវភាពយុត្តិធម៌ក្នុង

---

[44] *សូមមើល* "សេចក្តីណែនាំនៅមុនពេលសវនាការបឋមពាក់ព័ន្ធនឹងសាក្សីដែលភាគីស្នើសុំកោះហៅ" ឯកសារ E93 ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១១។

[45] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសំណើលើកទីដប់មួយរបស់ជន ត្រូវចោទសុំបំពេញកិច្ចស៊ើបសួរ ឯកសារ D158/5/1/15 ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ កថាខណ្ឌ ២៩ (ដែលបានកត់សម្គាល់ថា វិធានផ្ទៃក្នុង ៣៥ មិនបានចែងអំពីការផ្តួចផ្តើមបំពេញកិច្ចស៊ើបសួរតាមការស្នើសុំរបស់ភាគីនោះទេ)។

[46] វិធាន៧៩(១) នៃវិធានផ្ទៃក្នុង ។

កិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះសាលាដំបូងបានស្នើសុំឲ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ("WESU") ធ្វើការស៊ើបអង្កេតលើហេតុការណ៍ដែលបានកើតឡើងនៅពន្ធនាគារព្រៃសដែលជាទីកន្លែងដែលសាក្សីរូបនេះបានរងរបួស និងស្នើសុំឲ្យធ្វើរបាយការណ៍ពីការណ៍នោះជូនដល់អង្គជំនុំ-ជម្រះសាលាដំបូង។ នៅថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១១ អង្គភាពគាំពារសាក្សី និងអ្នកជំនាញបានដាក់របាយការណ៍របស់ខ្លួនពាក់ព័ន្ធនឹងហេតុការណ៍នេះជូនអង្គជំនុំជម្រះ[47]។ នៅក្នុងដំណើរការស៊ើបអង្កេត អ្នកដែលអាចជាសាក្សីរូបនេះ [redacted] ក៏បានថ្លែងប្រាប់អ្នកស៊ើបអង្កេតផងដែរថា ក្មួយស្រីម្នាក់របស់ [redacted] បានទាក់ទងមកគាត់។ ទោះបីជាយ៉ាងណាក៏ដោយ [redacted] បានលើកឡើងថា គាត់គ្មានអារម្មណ៍ភ័យខ្លាចដោយសារហេតុការណ៍នេះទេ ហើយក៏មិនបានស្នើសុំវិធានការការពារផងដែរ។ ហេតុដូច្នេះ អង្គភាពគាំពារសាក្សី និងអ្នកជំនាញបានសន្និដ្ឋានថា បច្ចុប្បន្ននេះ ពុំមានមូលដ្ឋានណាមួយគួរឲ្យព្រួយបារម្ភពាក់ព័ន្ធទៅនឹងបុគ្គលដែលអាចជាសាក្សីរូបនេះទេ ហើយក៏មិនបានណែនាំឲ្យមានវិធានការការពារណាមួយទាក់ទិនទៅនឹងបុគ្គលដែលអាចជាសាក្សីរូបនេះផងដែរ[48]។

២៣. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ហេតុការណ៍ទាំងឡាយដែលមេធាវីការពារក្តី នួន ជា បានយកធ្វើជាសំអាងបានក្លាយជាផ្នែកមួយនៃសំណុំរឿងតាំងតែពីថ្ងៃទី០៥ ខែ មករា ឆ្នាំ ២០០៩ មកម្លេះ[49]។ មេធាវី នួន ជា ខកខានមិនបានលើកឡើងអំពីការចោទប្រកាន់ពីការជ្រៀតជ្រែកទៅក្នុងកិច្ចការរដ្ឋបាលតុលាការដែលបង្ហាញពីការខ្វះការយកចិត្តទុកដាក់ និងមិនបានបង្ហាញពីភាពបន្ទាន់នៃសំណើនេះទេ រហូតដល់រយៈពេលជាងពីរឆ្នាំក្រោយមកទើបលើកពីបញ្ហានេះ[50]។ ចាប់ពីពេល

---

[47] ការវាយតម្លៃរបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ (WESU) [redacted] ឯកសារ E29/447 ចុះថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ២០១១។

[48] ការវាយតម្លៃរបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ (WESU) [redacted] ឯកសារ E29/447 ចុះថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ២០១១។

[49] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី [redacted] ឯកសារ D123/1 ចុះថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០០៩ ទំព័រ ១៣ ដល់ ១៤។

[50] សូមមើលរឿងក្តី រដ្ឋអាជ្ញាតទល់ជាមួយ Taylor សេចក្តីសម្រេចទៅលើសំណើរបស់មេធាវីការពារក្តី ដែលស្នើសុំឲ្យមានការស៊ើបអង្កេតទៅលើការិយាល័យរដ្ឋអាជ្ញា និងអ្នកស៊ើបអង្កេតរបស់រដ្ឋអាជ្ញា ចំពោះការមិនគោរពសេចក្តីសម្រេចរបស់តុលាការ។ សេចក្តីសម្រេចនេះត្រូវបានចាត់ថ្នាក់ជាប្រភេទឯកសារសាធារណៈ តែឧបសម្ព័ន្ធ A-J ជាឯកសារសម្ងាត់ ហើយឧបសម្ព័ន្ធ K-O ជាឯកសារសាធារណៈ អង្គជំនុំជម្រះសាលាដំបូង តុលាការ SCSL (Case No. SCSL-03-1-T) ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១០ កថាខណ្ឌ ២៣-២៦ (អង្គជំនុំជម្រះយល់ឃើញថា មេធាវីការពារក្តីមិនបានប្រព្រឹត្តដោយស្មោះត្រង់ក្នុងការលើកឡើងពីការមិនគោរពសេចក្តីសម្រេចរបស់តុលាការ ដែលកើតឡើង ២ ទៅ ៨ ឆ្នាំរួចហើយបន្ទាប់ពីព្រឹត្តិការណ៍បានកើតឡើង)។ សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ/ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១១/សាធារណៈ

នោះមក [redacted] ក៏ត្រូវបានសម្ភាសន៍ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ឬអង្គភាពគាំពារសាក្សី និងអ្នកជំនាញ នៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ និងនៅថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១១ ដាច់ដោយឡែកពីគ្នា។ នៅក្នុងការសម្ភាសន៍នោះមិនមានការបង្ហាញណាមួយថា គាត់ទទួលរងការគំរាមកំហែង ឬការបំភិតបំភ័យនោះទេ[51]។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងពិចារណាឃើញថា ពុំមានមូលដ្ឋានណាមួយនាបច្ចុប្បន្ននេះដើម្បីផ្តួចផ្តើមកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុងនោះឡើយ[52]។

## អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូង

**ប្រកាសថា** សំណើរបស់ជនជាប់ចោទនៅក្នុងអញ្ញត្រកម្មរួម (ឯកសារ E51/3) ដែលស្នើសុំឱ្យបញ្ចប់កិច្ចដំណើរការនីតិវិធី ឬជាជម្រើសម្យ៉ាងទៀត ស្នើសុំឱ្យបង្អង់កិច្ចដំណើរការនីតិវិធីនោះ គឺមិនអាចទទួលយកបានទេ ហើយទោះក្នុងករណីណាក៏ដោយ មិនមានសម្អាងហេតុគ្រប់គ្រាន់ដែលអាចទទួលយកបានឡើយ។

**បដិសេធ** ចោលទាំងស្រុងនូវសំណើរួមសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែម (ឯកសារ E88) និងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរអនុលោមតាមវិធាន ៣៥ (ឯកសារ E82) ។

**អនុញ្ញាតតាម** សំណើសុំបំពេញកិច្ចស៊ើបសួរលើកទីពីរដែលធ្វើឡើងអនុលោមតាមវិធាន៣៥ (ឯកសារ E92) ប៉ុន្តែបន្ទាប់ពីមានកិច្ចស៊ើបសួរដែលធ្វើឡើងដោយអង្គភាពគាំពារសាក្សី និងអ្នកជំនាញ អង្គជំនុំជម្រះសម្រេចថាពុំចាំបាច់ត្រូវចាត់វិធានការបន្ថែមទៀតនោះទេ។

**បដិសេធ** សំណើរបស់ជនជាប់ចោទសុំឱ្យមានសវនាការដេញដោលផ្ទាល់មាត់ពាក់ព័ន្ធទៅនឹងបញ្ហាទាំងអស់នេះ។

ភ្នំពេញ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១១
ប្រធានអង្គជំនុំជម្រះសាលាដំបូង

**និល ណុន**

[51] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី [redacted] ឯកសារ D234/22 ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៩ ។

[52] អង្គជំនុំជម្រះក៏បានស្នើសុំឱ្យអង្គភាពគាំពារសាក្សីនិងអ្នកជំនាញតាមដានបន្ថែមលើបញ្ហានេះ។ របាយការណ៍របស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញនឹងដាក់ចូលក្នុងសំណុំរឿងក្នុងពេលសមស្រប ។